**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០៤...... សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី

## ការតែងតាំងវេជ្ជបណ្ឌិតប្រចាំការបុរេប្រទាន
## ប្រចាំនៅនាយកដ្ឋានអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៤៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១៩៤ សហវ.ប្រកចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកដ្ឋានអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ ១._**

ត្រូវបានតែងតាំងមន្ត្រី ០២រូប ជារដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាពដូចខាងក្រោម៖

១.លោក **គា គឹមស៊្រុន** ឋានៈអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទាន

២.លោក **រ័ត្ន ប៊ុណ្ណា** ឋានៈអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង

**ប្រការ ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ និងនាយកដ្ឋានអប់រំពិសេស ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួន មានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ............ខែ............ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ២៤៦ អយក.១៣៨

លេខ ២០៤
មកដល់ថ្ងៃទីខែឆ្នាំ 21/01/19 ម៉ោង 9:25
បញ្ជូនទៅ
ថ្ងៃទីខែឆ្នាំ 21/01/19 ម៉ោង 9:25

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** សំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង នៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គ្រប់គ្រងរាល់កិច្ចដំណើរការតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។

**យោង** ៖-អនុក្រឹត្យលេខ៨២ អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្ដីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ដើម្បីធានាបាននូវនិរន្តរភាព ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានអប់រំពិសេស ក្នុងការអនុវត្តថវិកាកម្មវិធី ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំតែងតាំងមន្ត្រីរាជការពីររូប ជារដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ដើម្បីគ្រប់គ្រងការអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានដូចមានសមាសភាពខាងក្រោម៖

១.លោក គា គឹមស្រ៊ុន ជាអនុប្រធានការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទាន ✓

២.លោក វ័ន្ត ប៊ុណ្ណា ជាអនុប្រធានការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាព អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរងតាមសំណើខាងលើ ដោយសេចក្ដីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ សុក្រ ១៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**ចម្លងជូន**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ កាលប្បវត្តិ នាយកដ្ឋានអប់រំពិសេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៤៦ អយក.រាជ.ស

# សូមគោរពជូន

## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**កម្មវត្ថុ ៖** សំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង នៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គ្រប់គ្រងរាល់កិច្ចដំណើរការតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។

**យោង ៖**-អនុក្រឹត្យលេខ៨២ អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ដើម្បីធានាបាននូវនិរន្តរភាព ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានអប់រំពិសេស ក្នុងការអនុវត្តថវិកាកម្មវិធី ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំតែងតាំងមន្ត្រីរាជការពីររូប ជារដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ដើម្បីគ្រប់គ្រងការអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានដូចមានសមាសភាពខាងក្រោម៖

**១.លោក គា គឹមស្រ៊ុន** ជាអនុប្រធានការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទាន ✓

**២.លោក រ័ត្ន ប៊ុណ្ណា** ជាអនុប្រធានការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាព អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរងតាមសំណើខាងលើ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ សុក្រ ១៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ កាលប្បវត្តិ នាយកដ្ឋានអប់រំពិសេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយកដ្ឋានអប់រំ**
**នាយកដ្ឋានអប់រំពិសេស**
លេខៈ ១៣៤ អពស

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**តាមរយៈ** ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ។

**កម្មវត្ថុ:** សំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរងសម្រាប់អនុវត្តថវិកាប្រចាំឆ្នាំ នៅនាយកដ្ឋានអប់រំពិសេស។

**យោង:** ការចាំបាច់របស់អង្គភាពថវិកានាយកដ្ឋានអប់រំពិសេស ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងអនុវត្តថវិកាបានទាន់ពេលវេលា នាយកដ្ឋានអប់រំពិសេសស្នើសុំអនុញ្ញាតតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ដែលមានឈ្មោះដូចខាងក្រោម ៖

១.លោក **គា គឹមស្រ៊ុន** ជាអនុប្រធានការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទាន

២.លោក **វ័ត្ន ប៊ុណ្ណា** ជាអនុប្រធានការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង

អាស្រ័យហេតុនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចតាមសំណើខាងលើដោយក្ដីអនុគ្រោះ។ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃសុក្រ ៦រោចខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២
**រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨**
**ប្រធាននាយកដ្ឋានអប់រំពិសេស**

**ចោង_រិទ្ធី**

លេខៈ ២៥៧ អគ.អរ
បានឃើញ និងគោរពជូន
**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី**
"ដើម្បីស្នើសុំយោបល់ពិនិត្យ និងសម្រេច "។
ថ្ងៃច័ន្ទ ៩រោច ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័កព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
**អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ**

**ពុត_សាមិត្ថ**

-ឯកសារ
-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកអប់រំ និងជាប្រធានកម្មវិធីទី១
អង្គភាពថវិកានាយកដ្ឋានអប់រំពិសេស

## កំណត់បង្ហាញរឿង

## សូមគោរពជូនឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ ៖** សំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង សម្រាប់អនុវត្តថវិកាកម្មវិធី នៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គ្រប់គ្រងរាល់កិច្ចដំណើរការតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។

**យោង ៖** តាមការចាំបាច់របស់នាយកដ្ឋានអប់រំពិសេស។

**ខ្លឹមសារ ៖** កន្លងនាយកដ្ឋានអប់រំពិសេសបាន អនុវត្តថវិកាកម្មវិធីរួមគ្នាជាមួយនាយកដ្ឋានបឋមសិក្សាដល់ឆ្នាំ២០១៩ នាយកដ្ឋានអប់រំពិសេស បានក្លាយជាអង្គភាពថវិកា ហើយត្រូវគ្រប់គ្រង និងអនុវត្តថវិកាដោយខ្លួនឯងនូវរាល់ប្រតិបត្តិការចំណូល ចំណាយថវិកាក្នុងឆ្នាំ២០១៩។ ដូច្នេះ ដើម្បីឱ្យនាយកដ្ឋាននេះ អាចអនុវត្តថវិកាក្នុងឆ្នាំ២០១៩ បាន ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំតែងតាំងមន្ត្រីរាជការពីររូប ជារដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ដើម្បីគ្រប់គ្រងការអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានដូចមានរាយនាមខាងក្រោម៖

១.លោក គា គឹមស្រ៊ុន ជាអនុប្រធានការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទាន

២.លោក វ័ន្ធ ប៊ុណ្ណា ជាអនុប្រធានការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

គោរពជូនពិនិត្យ និងសម្រេច
ថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩
អ្នកធ្វើតារាង

| យោបល់ប្រធានការិយាល័យជំនាញ | |
|---|---|
| 10/01/19 | |
| **យោបល់ឯកឧត្តមអគ្គនាយកអប់រំ និងជាប្រធានកម្មវិធីទី១** | **យោបល់អង្គភាពថវិកា** |
| 10/01/2019 | 10.01.2019 |
| **យោបល់ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ** | **យោបល់ប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកអប់រំ** |
| 14/1/19 | 2019 |
| **យោបល់ឯកឧត្តមអនុរដ្ឋលេខាធិការ ឬរដ្ឋលេខាធិការ** | **យោបល់ឯកឧត្តមអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** 14.01.19 |
| 16.01.19 | 16.01.2019 |

**យោបល់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យ ក.ស.ហ.វ.
ចូលថ្ងៃទី 28.01.19 ម៉ោង........
លេខ.......19.00813.K........

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរតនាគារជាតិ

# កំណត់បង្ហាញ

**លិខិតលេខ** ÷ ២៤៦ អយក.អពស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ របស់នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា។

**កម្មវត្ថុ** ÷ សំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង របស់នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា។

**ខ្លឹមសារសង្ខេប** ÷ យោងតាមការចាំបាច់របស់នាយកដ្ឋានអប់រំពិសេស ក្រសួងស្នើសុំតែងតាំងមន្ត្រី០២រូប លោក**គា គីមស្រ៊ុន** ជារដ្ឋទេយ្យករបុរេប្រទាន និងលោក **វ័ត្ត ម៉ុណ្ណា** ជារដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជួយសម្រួលដល់កិច្ចដំណើរការរដ្ឋបាល និងសកម្មភាពនៃថវិកាកម្មវិធី។

---

**យោបល់នាយកដ្ឋានចំណាយថវិកា**
**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

យោងប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងប្រកាសលេខ៨៤៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

យោងតាមតម្រូវការចាំបាច់របស់នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា ទើបក្រសួងសម្រេចតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង ដើម្បីជួយសម្រួលដល់កិច្ចដំណើរការរដ្ឋបាល បានទាន់ពេលវេលា មានគណនេយ្យភាព ប្រសិទ្ធភាព និងតម្លាភាព ស្របតាមទិសដៅកំណែទម្រង់របស់រាជរដ្ឋាភិបាល ដូចមានសមាភាពខាងក្រោម÷

១-លោក**គា គីមស្រ៊ុន** ឋានៈ អនុប្រធានការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ ជារដ្ឋទេយ្យករបុរេប្រទាន

២-លោក **វ័ត្ត ម៉ុណ្ណា** ឋានៈ អនុប្រធានការិយាល័យរដ្ឋបាល ជារដ្ឋទេយ្យករបុរេប្រទានរង

ចំពោះសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង របស់នាយកដ្ឋានអប់រំពិសេស និងក្រសួងអប់រំ យុវជន និងកីឡា គឺមានភាពត្រឹមត្រូវ។ ជាយោបល់របស់នាយកដ្ឋានចំណាយថវិកា សូមឯកភាពចំពោះសំណើសុំតែងតាំងនេះ។

សូមគោរពជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលមេត្តាពិនិត្យ និងសម្រេច ដ៏ខ្ពង់ខ្ពស់។

| ប្រធាននាយកដ្ឋាន ចំណាយថវិកា | ប្រធានការិយាល័យ ចំណាយថវិកាទី២ | មន្ត្រីទទួលបន្ទុក |
|---|---|---|
| ឌឹម រិទ្ធីសេន | 21-01-2019 | កែវ គឹមហុង |

**យោបល់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គនាយកដ្ឋានរតនាគារជាតិ សូមឯកភាពលើការស្នើសុំតែងតាំងលោក **គា គីមស្រ៊ុន** ជារដ្ឋទេយ្យករបុរេប្រទាន និងលោក **វ័ត្ត ម៉ុណ្ណា** ជារដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា។

គោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ដោយគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ

**ជ.ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**អគ្គនាយករង**

22.01.19

**ម៉ីញ បានសុវណ្ណអាទិច្ចសីលា**

**យោបល់ឯកឧត្តមរដ្ឋលេខាធិការ**

24/01/2019

**ការសម្រេចរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

28/1/2019

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...១១៧.......សហវ.....ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់បុរេប្រទានសម្រាប់ឆ្នាំ២០១៩ របស់នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨ /០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៩៤ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា។

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ជំពូក៦០ “ការទិញ” ជំពូក៦១ “សេវាកម្ម”នៅនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២ ._**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធាននាយកដ្ឋានអប់រំពិសេស ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ